21.12.23
F3020

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ....០៦៧........អ.ស.ហ.ប្រក

## ប្រកាស

## ស្តីពី

## កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាត របស់បរធនបាល

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច

- បានឃើញប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច
- បានឃើញប្រកាសលេខ ០១០ អ.ស.ហ.ប្រក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច
- យោងតាមការស្នើរបស់និយ័តករបរធនបាលកិច្ច

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីកាតព្វកិច្ចរបស់បរធនបាល ក្នុងការផ្តល់របាយការណ៍ ការជូនដំណឹង និងការស្នើសុំការអនុញ្ញាតជាមុនពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដើម្បីត្រួតពិនិត្យ និងតាមដាននូវការបំពេញកាតព្វកិច្ចរបស់បរធនបាលឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច ព្រមទាំងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រកាសនេះ និងក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ អនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច ប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។

***បុគ្គលិកជាន់ខ្ពស់*** សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងអភិបាល។

## ជំពូកទី២
## កាតព្វកិច្ចផ្តល់របាយការណ៍

**ប្រការ៤.-**

បរធនបាល ត្រូវផ្តល់ជូន **ន.ម.ធ.** នូវរបាយការណ៍ប្រចាំខែ ដូចខាងក្រោម÷

១-របាយការណ៍ស្តីពីចំណូលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាល

២-របាយការណ៍ស្តីពីការផ្តល់សេវាចុះបញ្ជីបរធនបាលកិច្ច ប្រសិនមាន

៣-របាយការណ៍ស្តីពីការដាក់និងការដកបរធនរបស់បរធនបាលទាយក/អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ប្រសិនមាន។

**ប្រការ៥.-**

បរធនបាល ត្រូវផ្តល់ជូន **ន.ម.ធ.** នូវរបាយការណ៍ប្រចាំត្រីមាស ដូចខាងក្រោម÷

១-របាយការណ៍ហិរញ្ញវត្ថុផ្ទៃក្នុងពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ចដែលរៀបចំអនុលោមតាមស្តង់ដាគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-របាយការណ៍ស្តីពីការដោះស្រាយវិវាទ និងពាក្យបណ្តឹង ប្រសិនមាន និង

៣-របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច។

ករណីមិនមានការកំណត់ផ្សេងទៀតក្រៅពីនេះ ដោយ **ន.ម.ធ.** ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើប្រតិបត្តិការបរធនបាលកិច្ច ត្រឹមតែការផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច មិនតម្រូវឱ្យអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងចំណុចទី១ នៃកថាខណ្ឌទី១ នៃប្រការនេះ។

**ប្រការ៦.-**

ក្រុមហ៊ុនបរធនបាល ត្រូវផ្តល់ជូន **ន.ម.ធ.** នូវរបាយការណ៍ប្រចាំឆ្នាំ ដូចខាងក្រោម÷

១-របាយការណ៍អំពីសមិទ្ធផល និងបញ្ហាប្រឈម ដែលអនុវត្តតាមផែនការអាជីវកម្មដែលបានដាក់តម្កល់នៅ **ន.ម.ធ.**

២-អង្គការលេខ និងរចនាសម្ព័ន្ធបច្ចុប្បន្នដោយបញ្ចូលទាំងក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ សាខា និងការិយាល័យតំណាងទាំងអស់របស់ក្រុមហ៊ុនបរធនបាល

៣-របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល ដែលត្រូវបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលទទួលបានការទទួលស្គាល់ពី **ន.ម.ធ.**

៤-លិខិតបញ្ជាក់ពីក្រុមហ៊ុនពាក់ព័ន្ធ ដែលធានាកាតព្វកិច្ចបំណុលនៃក្រុមហ៊ុនបរធនបាល ឬបុត្រសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុនបរធនបាល និងឯកសារពាក់ព័ន្ធ ប្រសិនមាន

៥-កិច្ចសន្យាធានារ៉ាប់រងលើបរធន ប្រសិនមាន

៦-កិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើមុខងារជាបរធនបាល ប្រសិនមាន

៧-របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច

៨-របាយការណ៍ស្តីពីសកម្មភាពទំនួលខុសត្រូវសង្គម និងបរិស្ថាន និង

៩-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

ករណីមិនមានការកំណត់ផ្សេងទៀតក្រៅពីនេះ ដោយ **ន.ម.ធ.** ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើប្រតិបត្តិការបរធនបាលកិច្ច ត្រឹមតែការផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច មិនតម្រូវឱ្យអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងចំណុចទី១, ទី២, ទី៣, ទី៤ និងទី៩ នៃកថាខណ្ឌទី១ នៃប្រការនេះ។

បរធនបាលជារូបវន្តបុគ្គលឯករាជ្យ ត្រូវផ្តល់ជូន **ន.ម.ធ.** នូវរបាយការណ៍ប្រចាំឆ្នាំ ដូចខាងក្រោម÷

១-របាយការណ៍អំពីសមិទ្ធផល និងបញ្ហាប្រឈម ដែលអនុវត្តតាមផែនការអាជីវកម្មដែលបានដាក់តម្កល់នៅ **ន.ម.ធ.**

២-របាយការណ៍ហិរញ្ញវត្ថុ ដែលបានរៀបចំអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

៣-កិច្ចសន្យាធានារ៉ាប់រងលើបរធន ប្រសិនមាន

៤-កិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើមុខងារជាបរធនបាល ប្រសិនមាន

៥-របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច

៦-របាយការណ៍ស្តីពីសកម្មភាពទំនួលខុសត្រូវសង្គម និងបរិស្ថាន និង

៧-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **ន.ម.ធ.**។

**ប្រការ៧.-**

បរធនបាល ត្រូវផ្តល់ជូន **ន.ម.ធ.** នូវរបាយការណ៍ តាមកាលបរិច្ឆេទដូចខាងក្រោម÷

១-របាយការណ៍ប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់

២-របាយការណ៍ប្រចាំត្រីមាសយ៉ាងយូរត្រឹមថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់

៣-របាយការណ៍ប្រចាំឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ។

ក្នុងករណីដែលកាលបរិច្ឆេទចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកសាធារណៈ បរធនបាល ត្រូវផ្តល់របាយការណ៍នៅថ្ងៃធ្វើការបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ធ.**។

## ជំពូកទី ៣
## កាតព្វកិច្ចជូនដំណឹង

**ប្រការ៨.-**

ក្រុមហ៊ុនបរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ធ.** អំពីការប្រែប្រួលនៃស្ថានភាពណាមួយដែលអាចជះឥទ្ធិពលដល់ក្រុមហ៊ុនបរធនបាល ក្នុងការធ្វើប្រតិបត្តិការបរធនបាលកិច្ច និង/ឬដល់ទ្រព្យសម្បត្តិបរធនបាលកិច្ច ដូចខាងក្រោម÷

១-ស្ថានភាពគ្រប់គ្រងរបស់ក្រុមហ៊ុនបរធនបាល

២- ទ្រព្យសកម្មរបស់ក្រុមហ៊ុនបរធនបាល

៣- ស្ថានភាពឥណទាន ឬបំណុលរបស់ក្រុមហ៊ុនបរធនបាល

៤- ស្ថានភាពវិនិយោគរបស់ក្រុមហ៊ុនបរធនបាល

៥- រចនាសម្ព័ន្ធប្រាក់ចំណេញរបស់ក្រុមហ៊ុនបរធនបាល និង

៦- ការប្រែប្រួលផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពគ្រប់គ្រង និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល។

ការជូនដំណឹងត្រូវរួមបញ្ចូលទាំងការវាយតម្លៃអំពីឥទ្ធិពលនៃការប្រែប្រួលទាំងនោះ លើក្រុមហ៊ុនបរធនបាល និង/ឬទ្រព្យសម្បត្តិបរធនបាលកិច្ច ព្រមទាំងសកម្មភាព ឬវិធានការទាំងអស់ដែលក្រុមហ៊ុនបរធនបាលធ្វើឡើង ដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

បរធនបាលជារូបវន្តបុគ្គលឯករាជ្យ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ធ.** អំពីការប្រែប្រួលនៃស្ថានភាពណាមួយ ដែលអាចជះឥទ្ធិពលដល់បរធនបាលរូបវន្តបុគ្គលឯករាជ្យ ក្នុងការធ្វើប្រតិបត្តិការបរធនបាលកិច្ច ឬទ្រព្យសម្បត្តិបរធនបាលកិច្ច ដូចខាងក្រោម÷

១- ស្ថានភាពគ្រប់គ្រងរបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យ

២- ស្ថានភាពឥណទាន ឬបំណុលនៃទ្រព្យសម្បត្តិបរធនបាលកិច្ច

៣- ស្ថានភាពវិនិយោគនៃទ្រព្យសម្បត្តិបរធនបាលកិច្ច

៤- រចនាសម្ព័ន្ធប្រាក់ចំណេញ-ខាតនៃទ្រព្យសម្បត្តិបរធនបាលកិច្ច

៥- ការប្រែប្រួលផ្សេងទៀត ដែលពាក់ព័ន្ធនឹងស្ថានភាពគ្រប់គ្រងរបស់បរធនបាលរូបវន្តបុគ្គលឯករាជ្យ និងហិរញ្ញវត្ថុនៃទ្រព្យសម្បត្តិបរធនបាលកិច្ច។

ការជូនដំណឹង ត្រូវរួមបញ្ចូលទាំងការវាយតម្លៃអំពីឥទ្ធិពលនៃការប្រែប្រួលទាំងនោះ លើទ្រព្យសម្បត្តិបរធនបាលកិច្ច ព្រមទាំងសកម្មភាព ឬវិធានការទាំងអស់ដែលបរធនបាលជារូបវន្តបុគ្គលឯករាជ្យធ្វើឡើង ដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

**ប្រការ៩.-**

ករណីបរធនបាល ធ្វើការទាមទារសំណងក្នុងក្របខណ្ឌកិច្ចសន្យាធានារ៉ាប់រងលើបរធន និងកិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើមុខងារជាបរធនបាល ឬធ្វើការផ្លាស់ប្តូរកិច្ចសន្យានោះ បរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ធ.** ក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមានការទាមទារសំណង ឬការផ្លាស់ប្តូរកិច្ចសន្យានោះ។

**ប្រការ១០.-**

ក្រុមហ៊ុនបរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ធ.** ប្រសិនបើក្រុមហ៊ុននោះ ក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ បុគ្គលមានទំនាក់ទំនងពិសេស ញាតិសម្ព័ន្ធ សាខា ការិយាល័យតំណាង ភាគហ៊ុនិក/សហកម្មសិទ្ធិករ ប្រធានប្រតិបត្តិការ គណនេយ្យករមានជំនាញ

ព.ម.

បរធន បុគ្គលិកជំនាញផ្នែកច្បាប់ បរធនបាលរូបវន្តបុគ្គល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ ដែលក្នុងអំឡុងពេលបំពេញមុខងារ ស្ថិតក្នុងស្ថានភាពដូចខាងក្រោម÷

១-ត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬមានពិរុទ្ធភាព ឬត្រូវកាត់ឱ្យជាប់ទោស ដោយសារបទល្មើសដែលមានក្នុងច្បាប់ជាធរមាននៅក្នុងយុត្តាធិការណាមួយ

២-ស្ថិតនៅក្នុងដំណើរការនៃការចោទប្រកាន់ពីបទមជ្ឈិម... 

៣-ជាប់បណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ច ឬការអនុវត្តវិជ្ជាជីវៈក្នុងវិស័យបរធនបាលកិច្ចនៅក្នុងយុត្តាធិការណាមួយ

៤-ទទួលរងនូវពិន័យអន្តរការណ៍ ការព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត ឬការដកហូត ឬបដិសេធអាជ្ញាបណ្ណ/ការអនុញ្ញាត ដោយបញ្ញត្តិករ និយ័តករ ឬស្ថាប័នវិជ្ជាជីវៈក្នុង យុត្តាធិការណាមួយ ឬ

៥-យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលការជូនដំណឹងអំពីការចុះធ្វើអធិការកិច្ច ឬការស៊ើបអង្កេតណាមួយ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ រួមទាំងការធ្វើអធិការកិច្ច ឬស៊ើបអង្កេតពាក់ព័ន្ធនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬការិយាល័យតំណាងរបស់ខ្លួនផងដែរ។

**ប្រការ១១.-**

បរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ធ.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលមានហេតុការណ៍ ឬមូលហេតុណាមួយដែលបណ្តាលឱ្យបរធនបាល អាចឈានទៅរកការផ្អាក ឬការឈប់ធ្វើប្រតិបត្តិការបរធនបាលកិច្ច។

បរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ធ.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលមានហេតុការណ៍ ឬមូលហេតុណាមួយដែលបណ្តាលឱ្យបរធនបាលកិច្ចដែលបានចុះបញ្ជី អាចឈានទៅរកការបញ្ឈប់បរធនបាលកិច្ច ឬការជម្រះបញ្ជីបរធន។

**ប្រការ១២.-**

ក្រុមហ៊ុនបរធនបាល ត្រូវជូនដំណឹងជាបន្ទាន់មក **ន.ម.ធ.** ក្នុងករណីមានចំណុចណាមួយដូចខាងក្រោម កើតឡើងចំពោះបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា÷

១-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការធ្វើអនុប្បទានអាជីវកម្មដោយផ្នែក ឬទាំងស្រុង

២-ការហាមឃាត់ ឬការដាក់កម្រិតក្នុងការចេញមូលប្បទានប័ត្រ

៣-ការចេញសេចក្តីសម្រេចរំលាយក្រុមហ៊ុន

៤-ការចាប់ផ្តើមនៃនីតិវិធីណាមួយទាក់ទងនឹងនីតិវិធីនៃការក្ស័យធន

៥-ករណីផ្សេងទៀតដែលតម្រូវដោយ **ន.ម.ធ.**។

**ប្រការ១៣.-**

ក្រុមហ៊ុនបរធនបាល/ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យ

បរធនបាលកិច្ចត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ធ.** អំពីការលាឈប់ ឬការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលទទួលស្គាល់គុណវុឌ្ឍិ/បរធនបាលរូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណរបស់ខ្លួនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានលិខិតលាឈប់ពីការងារ ឬការសម្រេចបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលទទួលស្គាល់គុណវុឌ្ឍិ/បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល/ប្រតិបត្តិករបរធនបាលនោះ។

**ប្រការ១៤ .-**

បរធនបាល ត្រូវប្រកាសអំពីទំនាក់ទំនង ឬព័ត៌មានជាមូលដ្ឋានជាមួយភ្នាក់ងារ/អ្នកផ្តល់សេវាពាក់ព័ន្ធនឹងបរធនបាលកិច្ចរួមមាន អ្នកគ្រប់គ្រងមូលនិធិ ភ្នាក់ងារសេវាកម្មពន្ធដារ គណនេយ្យករ និងអ្នកប្រឹក្សាផ្នែកវិនិយោគ។

## ជំពូកទី ៤
## ភាតព្វកិច្ចស្នើសុំការអនុញ្ញាត

**ប្រការ១៥.-**

ក្រុមហ៊ុនបរធនបាល ត្រូវស្នើសុំការអនុញ្ញាតពី **គ.ម.ធ.** មុននឹងរំលាយក្រុមហ៊ុនបញ្ចូលគ្នា, ទិញក្រុមហ៊ុន, ផ្ទេរប្រតិបត្តិការបរធនបាលកិច្ច, ចាប់ផ្តើមការជម្រះបញ្ជី, រំលាយក្រុមហ៊ុន, ការផ្អាក ឬការឈប់ធ្វើប្រតិបត្តិការបរធនបាលកិច្ច។

ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ត្រូវស្នើសុំការអនុញ្ញាតពី **គ.ម.ធ.** មុនចាប់ផ្តើមការផ្អាក ឬការឈប់ធ្វើប្រតិបត្តិការបរធនបាលកិច្ច។

**ប្រការ១៦.-**

បរធនបាល ត្រូវផ្តល់ជូន **គ.ម.ធ.** នូវនីតិវិធី និងឯកសារពាក់ព័ន្ធនឹងការឈប់ធ្វើប្រតិបត្តិការបរធនបាលកិច្ចក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ មុនថ្ងៃឈប់ធ្វើប្រតិបត្តិការ។ នីតិវិធី និងរយៈពេលនៃការអនុវត្តនីតិវិធីឈប់ធ្វើប្រតិបត្តិការ ត្រូវទទួលការយល់ព្រមពី **គ.ម.ធ.**។ ក្នុងករណី ការអនុវត្តនីតិវិធីនៃការឈប់ធ្វើប្រតិបត្តិការ ប្រើប្រាស់ពេលលើសពីរយៈពេលទទួលបានការអនុញ្ញាត **គ.ម.ធ.** មានសិទ្ធិកំណត់រយៈពេលបន្ថែម។

ការឈប់ធ្វើប្រតិបត្តិការបរធនបាលកិច្ច ត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច ក្នុងករណីជម្រះបញ្ជីដោយស្ម័គ្រចិត្ត។

**ប្រការ១៧ .-**

មុនពេលបង្កើតបុត្រសម្ព័ន្ធ សាខា និងការិយាល័យតំណាងពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ចក្រុមហ៊ុនបរធនបាល ត្រូវស្នើសុំការអនុញ្ញាតពី **គ.ម.ធ.** ដោយត្រូវបំពេញលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ធ.**។

រាល់របាយការណ៍ដែលក្រុមហ៊ុនបរធនបាលត្រូវផ្តល់ជូន **ន.ប.ធ.** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ត្រូវរួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងបុត្រសម្ព័ន្ធ សាខា និងការិយាល័យតំណាងនៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៥
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ១៨.-**

បរធនបាល ត្រូវបង់ប្រាក់ភាគទានជាប្រចាំខែ ០,៤ (សូន្យក្បៀសបួន) ភាគរយនៃប្រាក់ចំណូលសរុបប្រចាំខែពីប្រតិបត្តិការបរធនបាលកិច្ចក្នុងវិស័យបរធនបាលកិច្ច ចូលក្នុងគណនីរបស់ **ន.ប.ធ.** សម្រាប់អភិវឌ្ឍវិស័យបរធនបាលកិច្ច និងទ្រទ្រង់កិច្ចដំណើរការរបស់ **ន.ប.ធ.**។

ប្រាក់ភាគទានប្រចាំខែខាងលើ បរធនបាល ត្រូវបង់រៀងរាល់ ១ (មួយ) ត្រីមាសម្តង យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ប.ធ.**។ **ន.ប.ធ.** អាចធ្វើការផ្ទៀងផ្ទាត់ការបង់ភាគទាននេះ ជាមួយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មរួច និង/ឬរបាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចប្រចាំឆ្នាំ និងអាចតម្រូវឱ្យបរធនបាលបង់ប្រាក់ភាគទានបន្ថែម ក្នុងករណីលទ្ធផលនៃការគណនាប្រាក់ភាគទានដែលបរធនបាលត្រូវបង់ប្រចាំឆ្នាំមានចំនួនច្រើនជាងផលបូកនៃប្រាក់ភាគទានដែលបានបង់រួចប្រចាំខែ។

**ប្រការ១៩.-**

បរធនបាល ត្រូវរៀបចំរាល់របាយការណ៍ និងព័ត៌មានអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវភាពសុក្រឹត ច្បាស់លាស់ និងពេញលេញ។ ប្រសិនមានកំហុសឆ្គង ឬការខ្វះខាតណាមួយត្រូវបានរកឃើញ បរធនបាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ប.ធ.** និងត្រូវផ្តល់សាជាថ្មីនូវរបាយការណ៍ និងព័ត៌មានដែលកែតម្រូវរួច។

**ប្រការ២០.-**

បរធនបាល ត្រូវផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗតាមការស្នើសុំរបស់ **ន.ប.ធ.** ដើម្បីកំណត់ពីភាពត្រឹមត្រូវរបស់បរធនបាលក្នុងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬសេចក្តីណែនាំរបស់ **ន.ប.ធ.**។

**ប្រការ២១.-**

បរធនបាល ត្រូវរៀបចំរបាយការណ៍ និងផ្តល់ព័ត៌មានអនុលោមតាមប្រកាសនេះ ក្នុងទម្រង់ដែលកំណត់ដោយ **ន.ប.ធ.**។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**ប្រការ២២.-**

បរធនបាលដែលមិនអនុវត្តតាមកាតព្វកិច្ចជូនដំណឹង/ ផ្តល់របាយការណ៍/ ស្នើសុំការអនុញ្ញាត ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលរងនូវវិធានការរដ្ឋបាលពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចខាងក្រោម÷

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើអាជ្ញាបណ្ណ/ ការអនុញ្ញាត
- ការព្យួរអាជ្ញាបណ្ណ/ ការអនុញ្ញាត
- ការដកហូតអាជ្ញាបណ្ណ/ ការអនុញ្ញាត
- ការដាក់កំហិតលើការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានចុះបញ្ជី។

**ប្រការ២៣.-**

ត្រូវផាកពិន័យជាប្រាក់ពី ៤០០.០០០ (បួនរយពាន់) រៀល ទៅ ៦០.០០០.០០០(ហុកសិបលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបរធនបាល ដែលមិនអនុវត្តតាមកាតព្វកិច្ចជូនដំណឹង/ ផ្តល់របាយការណ៍/ ស្នើសុំការអនុញ្ញាត ដូចមានចែងក្នុងប្រការ៧, ប្រការ៩, ប្រការ១៣, ប្រការ១៦ និងកថាខណ្ឌទី២នៃប្រការ១៨ នៃប្រកាសនេះ។

ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ទៅ ២០០.០០០.០០០(ពីររយលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះបរធនបាលដែលមិនអនុវត្តតាមកាតព្វកិច្ចជូនដំណឹង/ ផ្តល់របាយការណ៍/ ស្នើសុំការអនុញ្ញាត ដូចមានចែងក្នុងប្រការ៨, ប្រការ១០, ប្រការ១១,ប្រការ១២ និងប្រការ១៤នៃប្រកាសនេះ ឬមិនគោរពតាមសេចក្តីណែនាំ ការកំណត់ ឬការតម្រូវរបស់ **ន.ប.ធ.**។

ត្រូវរងវិធានការរដ្ឋបាលណាមួយដូចមានចែងក្នុងប្រការ២២ នៃប្រកាសនេះដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ចបន្ថែមលើការផាកពិន័យដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើ ចំពោះបរធនបាល ដែលបានប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវទទួលរងការផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំនួនទ្វេដងនៃទឹកប្រាក់ផាកពិន័យលើកមុន។

ការគ្រប់គ្រងការផាកពិន័យ ត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបរាងកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបរាងកាយ) នៃគន្ថីទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**ប្រការ២៤.-**

វិធានការរដ្ឋបាល និងការដាក់ពិន័យ ដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី ៧

## អវសានបញ្ញត្តិ

**ប្រការ២៥.-**

**គ.ម.ធ.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៧.-**

អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករ និងប្រធានអង្គភាព ក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៨ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:-**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២៧
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ